**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៥៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលផ្ទៃបឹងជើងឯក និងប្រឡាយ ស្ថិតក្នុងខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ និងក្រុងតាខ្មៅ ខេត្តកណ្តាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៦ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការកំណត់ផ្ទៃបឹងជើងឯក និងប្រឡាយ ស្ថិតក្នុងខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ និងស្រុកតាខ្មៅ ខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០១៩ ស្តីពីនិរាករណ៍អនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០១៨ ស្តីពីការកែសម្រួលផ្ទៃបឹងជើងឯក ស្ថិតនៅក្នុងខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ និងក្រុងតាខ្មៅ ខេត្តកណ្តាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

ត្រូវបានកាត់ផ្ទៃដីទំហំ ១ ៩០៤ ២១១ (មួយលានប្រាំបួនរយបួនពាន់ពីររយដប់មួយ) ម៉ែត្រក្រឡា ស្ថិតនៅសង្កាត់ជើងឯក និងសង្កាត់ដង្កោ ខណ្ឌដង្កោ និងសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការកំណត់ផ្ទៃបឹងជើងឯក និងប្រឡាយស្ថិតនៅខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ និងស្រុកតាខ្មៅ (បច្ចុប្បន្នក្រុងតាខ្មៅ) ខេត្តកណ្តាល ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីនិងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងផ្តល់ជាកម្មសិទ្ធិឯកជនជូនលោកឧកញ៉ា **លាង ឃុន** និងលោកឧកញ៉ា **ថៃ ជាហួត**។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៤ កើត ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ផែនទីបង្ហាញទីតាំងផ្ទៃបឹងជើងឯកទំហំ ១ ៩០៤ ២១១ ម៉ែត្រក្រឡា ដែលឧកញ៉ា លាង ឃុន និង ឧកញ៉ា ថៃ ជាហួត ស្នើសុំកម្មសិទ្ធិ និងអភិវឌ្ឍ




តារាងនិយាមកាព្រំដី
១ ៩០៤ ២១១ម²
Projection, UTM, Zone 48N
Datum, WGS 1984

| ID | E | N |
|---|---|---|
| 1 | 490562.356 | 1272941.600 |
| 2 | 490543.137 | 1272961.670 |
| 3 | 490530.699 | 1272977.895 |
| 4 | 490463.480 | 1273042.590 |
| 5 | 490358.967 | 1272919.785 |
| 6 | 490360.427 | 1272933.046 |
| 7 | 490444.387 | 1272934.205 |
| 8 | 490257.267 | 1272979.365 |
| 9 | 490256.977 | 1272913.596 |
| 10 | 490251.327 | 1272894.905 |
| 11 | 490229.447 | 1272889.295 |
| 12 | 490195.507 | 1272883.435 |
| 13 | 490161.517 | 1272877.565 |
| 14 | 490147.787 | 1272875.315 |
| 15 | 490134.507 | 1272873.366 |
| 16 | 490127.035 | 1272872.358 |
| 17 | 490109.537 | 1272872.436 |
| 18 | 490091.837 | 1272871.825 |
| 19 | 490073.927 | 1272871.516 |
| 20 | 490051.417 | 1272871.655 |
| 21 | 490022.397 | 1272871.736 |
| 22 | 490009.387 | 1272871.465 |
| 23 | 489993.807 | 1272870.665 |
| 24 | 489974.530 | 1272871.480 |
| 25 | 489955.320 | 1272872.230 |
| 26 | 489926.990 | 1272868.480 |
| 27 | 489869.457 | 1272861.466 |
| 28 | 489864.027 | 1272945.856 |
| 29 | 489837.417 | 1272938.805 |
| 30 | 489745.897 | 1272932.006 |
| 31 | 489742.066 | 1272973.024 |
| 32 | 489711.883 | 1272965.067 |
| 33 | 489697.932 | 1272768.497 |
| 34 | 489786.182 | 1272515.360 |
| 35 | 489668.808 | 1272453.219 |
| 36 | 489669.787 | 1272191.638 |
| 37 | 489591.626 | 1272191.668 |
| 38 | 489571.827 | 1272298.806 |
| 39 | 489462.017 | 1272400.731 |
| 40 | 489340.538 | 1272411.021 |
| 41 | 489204.929 | 1272026.513 |
| 42 | 489211.950 | 1271909.334 |
| 43 | 489252.713 | 1271824.867 |
| 44 | 489261.371 | 1271689.471 |
| 45 | 489413.226 | 1271462.865 |
| 46 | 489563.494 | 1271391.343 |
| 47 | 489735.647 | 1271444.168 |
| 48 | 489965.157 | 1271492.070 |
| 49 | 490117.029 | 1271623.215 |
| 50 | 490208.028 | 1271640.383 |
| 51 | 490346.518 | 1271496.100 |
| 52 | 490411.187 | 1271382.176 |
| 53 | 490446.245 | 1270790.526 |
| 54 | 490463.880 | 1270715.333 |
| 55 | 490642.683 | 1270715.036 |
| 56 | 490644.977 | 1271695.134 |
| 57 | 490695.958 | 1272634.445 |
| 58 | 490695.958 | 1272855.357 |
| 59 | 490664.466 | 1272869.663 |
| 60 | 490633.258 | 1272886.400 |
| 61 | 490611.040 | 1272901.500 |
| 62 | 490580.524 | 1272926.626 |